

# Eastbound SR-91/Atlantic Av to Cherry Av Auxiliary Lane Improvements
# គម្រោងសុវត្ថិភាពសម្រាប់ ហ្វ្រីវេ91 ឆ្ពោះទៅទិសខាងកើត

## ទិដ្ឋភាពទូទៅ

គម្រោងសុវត្ថិភាពសម្រាប់ ហ្វ្រីវេ91 ឆ្ពោះទៅទិសខាងកើត នឹងកែលម្អផ្នែកផ្សេងៗនៃផ្លូវល្បឿនលឿនដ៏គ្រោះថ្នាក់បំផុតមួយរបស់ North Long Beach នៅជិតជំនួបផ្លូវ I-710 ទៅទិសខាងត្បូងនឹងផ្លូវ SR-91 ទៅទិសខាងកើត។ គម្រោងនេះត្រូវបានរចនាឡើងដើម្បីកាត់បន្ថយគ្រោះថ្នាក់ បន្ធូរបន្ថយការកកស្ទះ និងកែលម្អស្ថានភាពសម្រាប់អ្នកបើកបរ និងសង្កាត់ជុំវិញ។ Metro និង Caltrans កំពុងផ្តល់ការវិនិយោគចំនួន 174 លានដុល្លារនេះនៅក្នុងសហគមន៍។ គម្រោងនេះត្រូវបានគេរំពឹងថានឹងចាប់ផ្តើមនៅដើមឆ្នាំ 2026 ដោយរំពឹងថានឹងបញ្ចប់នៅឆ្នាំ 2029។




## អំពីគម្រោងនេះ

គម្រោងសុវត្ថិភាពផ្លូវ 91 ឆ្ពោះទៅទិសខាងកើតនេះ មិនបន្ថែមលេន (lane) ថ្មីសម្រាប់ការធ្វើដំណើរចម្ងាយឆ្ងាយទេ។

ការផ្លាស់ប្តូរសំខាន់គឺលេនជំនួយថ្មីមួយ ដែលជាលេនតភ្ជាប់ខ្លីដែលជួយយានជំនិះចូល ចេញ ឬបញ្ចូលគ្នាដោយសុវត្ថិភាព។ លេនជំនួយនេះនឹងរត់ទៅទិសខាងកើតរវាង Atlantic Avenue និង Cherry Avenue ផ្គូផ្គងជាមួយនឹងផ្លូវឡើងហ្វ្រីវេដែលចេញមកពី Atlantic Avenue ដែលបានតបន្ថែម។ ការកែលម្អថ្មីនឹងផ្តល់ឱ្យអ្នកបើកបរកន្លែងនិងពេលវេលាកាន់តែច្រើនដើម្បីបញ្ចូលគ្នា, កាត់បន្ថយការជាន់ហ្វ្រាំងបន្ទាន់, ការផ្លាស់ប្តូរលេននៅវិនាទីចុងក្រោយ, និងការបើកចេញចូលលេន ដែលធ្វើឲ្យច្រករបៀងនេះប្រកបដោយគ្រោះថ្នាក់សព្វថ្ងៃនេះ។ ការកែលម្អទាំងនេះក៏នឹងជួយបំបាត់ភាពហៀប្រចាលចរាចរទៅលើផ្លូវក្នុងតំបន់ និងកាត់បន្ថយការប៉ះទង្គិចដែលអាចកើតឡើងពីអ្នកបើកបរដែលចេញចូលហ្វ្រីវេ។

## ឧទាហរណ៍៖ ពេលនេះ

ប្រសិនបើអ្នកចូលហ្វ្រីវេពីផ្លូវអាត្លង់ទិក អ្នកត្រូវចូលរួមជាមួយចរាចរដែលកំពុងបើកបរយ៉ាងលឿនភ្លាមៗ ដែលជាការពិបាកខ្លាំងនៅពេលដែលចរាចរច្រើន ហើយអ្នកបើកបរផ្សេងទៀតកំពុងព្យាយាមចេញពីហ្វ្រីវេនៅជិតនោះ។ បន្ទាប់ពីសាងសង់ អ្នកបើកបរដែលចូលហ្វ្រីវេពីអាត្លង់ទិកនឹងមានលេនមួយវែងផ្ទាល់សម្រាប់ចូល ដែលធ្វើឱ្យមានការងាយស្រួល និងមានសុវត្ថិភាពក្នុងការចូលហ្វ្រីវេ។ គម្រោងនេះក៏នឹងបន្ថែមថ្នល់ចាក់កៅស៊ូលើច្រកចូលពីផ្លូវអាត្លង់ទិក និងច្រកចេញទៅផ្លូវឈែរី ដែលក៏នឹងជួយកាត់បន្ថយសំឡេងចរាចរដល់អ្នកនៅជិតនោះផងដែរ។

ក្រៅពីបង្កើនសុវត្ថិភាពនៅលើហ្វ្រីវេនិងវិថីទាំងឡាយក្នុងតំបន់ គម្រោងនេះផ្តោតទៅលើការតុបតែងលម្អ។ នេះមានរួមទាំងការដាំដើមឈើ២ ជំនួស ១ មានន័យថា បើមានដើមឈើមួយដើមត្រូវរំលើងនៅពេលធ្វើការសាងសង់ គេនឹងដាំថ្មីពីរដើមជំនួសវិញ។

**អ្វីដែលអ្នកនៅជិតហ្វ្រីវេគួរតែដឹងអំពីជញ្ជាំងសម្លេង**

ចំពោះប្រជាជនដែលរស់នៅតាមបណ្តោយហ្វ្រីវេ91 កិច្ចការស្ថាបនាជញ្ជាំងសម្លេងហាក់ដូចជាកិច្ចការដ៏លេចធ្លោជាងគេបង្អស់ និងផ្ទាល់ខ្លួនបង្អស់ នៅក្នុងគម្រោងនេះ។

ជញ្ជាំងសម្លេងដែលមានស្រាប់នៅចន្លោះផ្លូវ អាត់ឡង់ទិក និងផ្លូវឈែរី នឹងត្រូវយកចេញ ហើយនឹងត្រូវបានជំនួសដោយជញ្ជាំងសម្លេងថ្មីដែលខ្ពស់ជាងមុនពីរហ្វីត។ ជញ្ជាំងដែលនៅចំណុចផ្លូវចុះពីហ្វ្រីវេខាងកើតទៅកាន់ផ្លូវអាត់ឡង់ទិកក៏នឹងត្រូវបានស្ថាបនាឡើងវិញ ដែលជាផ្នែកមួយនៃគម្រោងនេះដែរ។ មេត្រូយល់ថាជញ្ជាំងសម្លេងទាំងនេះមានសារៈសំខាន់។ វាកាត់បន្ថយសម្លេងរបស់ហ្វ្រីវេសព្វថ្ងៃហើយអវត្តមានបណ្តោះអាសន្នរបស់វាក្នុងរយៈពេលសាងសង់ នឹងបណ្តាលឲ្យសម្លេងកើនឡើងដែលប៉ះពាល់ដល់ផ្ទះទាំងឡាយដែលនៅជិតនោះ។ នេះជាការពិត និងត្រូវបានគេទទួលស្គាល់។

ដើម្បីកំណត់ផលប៉ះពាល់នោះ ការរុះរើជញ្ជាំងសម្លេង និងការស្ថាបនាឡើងវិញ នឹងប្រព្រឹត្តទៅតាមដំណាក់កាលផ្សេងៗ គឺរុះរើវាម្តងមួយភាគតែប៉ុណ្ណោះ។ កាលណាជញ្ជាំងថ្មីធ្វើបានសម្រេចហើយ វានឹងមានកំពស់ខ្ពស់ជាង ព្រមទាំងធ្វើអំពីគ្រឿងសម្ភារៈល្អជាងសម្ភារៈដែលប្រើសព្វថ្ងៃសម្រាប់កាត់បន្ថយសម្លេងបានច្រើនជាង។

**ការត្រួតពិនិត្យសម្លេង និងរំញ័រ**

មេត្រូតម្រូវឲ្យមានការត្រួតពិនិត្យសំឡេង និងរំញ័រយ៉ាងពេញលេញ មុនការសាងសង់ ដើម្បីកំណត់ស្ថានភាពមូលដ្ឋានក្នុងអំឡុងការសាងសង់ និងសម្រាប់មួយរយៈពេលបន្ទាប់ពីការសាងសង់។ ការវាយតម្លៃស្ថានភាពមូលដ្ឋាននេះកំណត់លក្ខខ័ណ្ឌដែលមានស្រាប់ ដើម្បីឲ្យដឹងថាបើមានការប្រែប្រួលណាមួយក្នុងអំឡុងការសាងសង់នឹងត្រូវយកមកដោះស្រាយ។

ក្នុងអំឡុងពេលសំណង់ ការត្រួតពិនិត្យត្រូវបានធ្វើជាប្រចាំ ហើយកំរិតសម្លេងដែលបានកំណត់ នឹងត្រូវអនុវត្តក្នុងរយៈពេលសំណង់។ ក្រុមមេត្រូ និងក្រុមសំណង់នឹងទទួលបានការជូនដំណឹងក្នុងពេលវេលាពិត តាមរយៈកម្មវិធីបណ្តាញអិនធឺណែត នៅពេលណាដែលសម្លេងរំខានឡើងស្មើឬលើសកំរិតកំណត់។ ប្រសិនបើសម្លេងនោះឡើងហួសកំរិតកំណត់ ការងារត្រូវឈប់ភ្លាមៗ។ អ្នកម៉ៅការត្រូវអនុវត្តន៍សកម្មភាពកែតម្រូវមុនពេលបន្តកិច្ចការតទៅទៀត ហើយមេត្រូត្រួតពិនិត្យលទ្ធផល។

មានប្រដាប់ត្រួតពិនិត្យរំញ័រទាំងអស់ចំនួន 27 ត្រូវបានដំឡើងមុនពេលសំណង់ចាប់ផ្តើម។

**មានការព្រួយបារម្ភមែនទេ?**

អ្នកអាចហៅទូរស័ព្ទទៅកាន់លេខរបស់គម្រោងបាន 24 ម៉ោង ក្នុងមួយថ្ងៃ7 ថ្ងៃក្នុងមួយសប្តាហ៍។ ការព្រួយបារម្ភរបស់អ្នកនឹងត្រូវបានកត់ត្រាទុក និងតាមដានបន្ត។

**កម្មវិធីច្រោះខ្យល់**

មានមូលនិធិផ្តល់សម្រាប់ឧបករណ៍ច្រោះខ្យល់ដោយមិនគិតថ្លៃ សម្រាប់ផ្ទះ និងអាជីវកម្មដែលមានសិទ្ធិ ដែលនៅជិតហ្វ្រីវេ។ មេត្រូ ក៏បានពង្រីកមណ្ឌលសំណង់ដើម្បីរួមបញ្ចូលនៅផ្ទះ និងអាជីវកម្មបន្ថែម។

**ស្កេនកូដ QR**

ដើម្បីដឹងបន្ថែមទៀត និងសូមចុះឈ្មោះ ដើម្បីតាមដានបច្ចុប្បន្នភាព នៃការសាងសង់